# ចែករំលែកចំណេះដឹងនៃបទពិសោធន៍
# SHARE EXPERIENCE KNOWLEDGE

**បទពិសោធន៍នៃព័ត៌មានវិទ្យា**
**(IT Experience)**

ប្រធានបទសម្រាប់ចែករំលែក (Subject to be shared) : **របៀបស្វែងយល់លំដាប់លេខរៀងនៃគេហទំព័រ**

កាលបរិច្ឆេទនៃការចែករំលែក (Date of this sharing) : ២៥ មិនា ២០១២

ចែករំលែកបទពិសោធន៍ដោយ (Experience shared by) : លោក សៀង ប៊ូហឿង

## ១. និយមន័យ (Definition)

ការស្វែងយល់ឬការដឹងអំពីលំដាប់លេខរៀងនៃគេហទំព័រ គឺដើម្បីដឹងថាតើគេហទំព័រណាមួយទទួលបានលេខរៀងទីប៉ុន្មាននៅលើពិភពលោក និងទទួលទទួលបានលេខរៀងទីប៉ុន្មាននៅក្នុងប្រទេសណាមួយដែលយើងចង់ដឹង។

## ២. ដំណើរការប្រតិបត្តិ (Procedure)

ដើម្បីងាយស្រួល យើងខ្ញុំសូមលើកយកគេហទំព័រ **www.bigsek.org** ជាឧទាហរណ៍ក្នុងការស្វែងយល់អំពីលំដាប់លេខរៀងនៃគេហទំព័រនេះគិតត្រឹមថ្ងៃទី១២ ខែមេសា ឆ្នាំ២០១២ ដោយអ្នកអាចជ្រើសរើសរបៀបណាមួយក៏បានក្នុង ចំណោមរបៀបទាំងបីខាងក្រោម ៖

**របៀបទី ១ ស្ដីពីការប្រើប្រាស់គេហទំព័រ www.alexa.com ដើម្បីស្វែងយល់អំពីលំដាប់លេខរៀង**

-ដំបូងសូមចូលទៅកាន់គេហទំព័រ www.alexa.com

-វាយអក្សរ **bigsek.org** ចូលទៅប្រអប់ដូចគំនូសព្រួញខាងក្រោម រួចចុចបញ្ចូនជាការស្រេច។



## របៀបទី ២ ស្តីពីការប្រើប្រាស់ **alexa toolbar** ដើម្បីស្វែងយល់អំពីលំដាប់លេខរៀង

-ដំបូងសូមចូលទៅកាន់គេហទំព័រ www.alexa.com

-ទាញយកកម្មវិធីដំឡើង **toolbar** នៅផ្នែកខាងក្រោម និងខាងស្តាំ ដូចក្នុងគំនូសបំព្រួញ



-បន្ទាប់មកដំឡើងកម្មវិធីនោះ ចូលទៅក្នុងម៉ាស៊ីនកំព្យូទ័ររបស់អ្នកជាការស្រេច




-អ្នកនឹងអាចមើលឃើញពីលំដាប់ក្នុងពិភពលោក នៃគេហទំព័រដែលអ្នកកំពុងបើក

-ប្រសិនបើអ្នកចង់ដឹងពីលំដាប់ក្នុងប្រទេសកម្ពុជាសូមចុចតាមគំនូសព្រួញខាងក្រោម



-បន្ទាប់មកអ្នកនឹងទទួលបានព័ត៌មានពិស្តារដូចក្នុងរូបខាងក្រោម




របៀបទី ៣ ស្តីពីការប្រើប្រាស់ alexa statusbar ដើម្បីស្វែងយល់អំពីលំដាប់លេខរៀង

-ដំបូងសូមចូលទៅកាន់គេហទំព័រ www.alexa.com

-ទាញយកកម្មវិធីដំឡើង statusbar នៅផ្នែកខាងក្រោម និងខាងស្តាំ ដូចក្នុងគំនូសបំព្រួញ



-បន្ទាប់មកដំឡើងកម្មវិធីនោះ ចូលទៅក្នុងម៉ាស៊ីនកំព្យូទ័ររបស់អ្នកជាការស្រេច




-ប្រសិនបើអ្នកចង់ដឹងពីលំដាប់ក្នុងប្រទេសកម្ពុជាសូមចុចតាមរូបដែលបង្ហាញដូខខាងក្រោម



-បន្ទាប់មកអ្នកនឹងទទួលបានព័ត៌មានពិស្តារដូចក្នុងរូបខាងក្រោម




## ៣. សេចក្តីសន្និដ្ឋាន (Conclusion)

នេះគ្រាន់តែជាបទពិសោធន៍ដ៏ស្តួចស្តើងមួយ ក្នុងការស្វែងយល់ដឹងអំពីលំដាប់លេខរៀងរបស់គេហទំព័រណាមួយតាមរយៈ www.alexa.com ។ យ៉ាងណាក៏ដោយវាក៏ជាបទពិសោធន៍មួយផងដែរសម្រាប់អ្នកទាំងឡាយដែលមានតម្រូវការបទពិសោធន៍គ្មានព្រំដែន។